ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០១ សរណន

# សារាចរណែនាំ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងនាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ កន្លងទៅនេះ គឺជារដ្ឋាភិបាលមួយ ដែលឆ្លុះបញ្ចាំងនូវឆន្ទៈនយោបាយនៃគណបក្សនយោបាយធំៗទាំងពីរជាដៃគូគឺ គណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច ស្របតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជាភាគច្រើនលើសលប់ ។

ដើម្បីពង្រឹងពង្រីកថែមទៀតនូវចំណងទាក់ទងសហប្រតិបត្តិការ និងភាពជាដៃគូយូរអង្វែង រវាងគណបក្សនយោបាយទាំងពីរនេះ ថ្នាក់ដឹកនាំនៃគណបក្សទាំងពីរបានព្រមព្រៀងគ្នាលើនីតិវិធី និងលក្ខណៈវិនិច្ឆ័យមួយចំនួនទាក់ទងនឹងការតែងតាំងមន្ត្រីរាជការក្នុងតំណែងមុខងារសាធារណៈ ក៏ដូចជាមុខតំណែងនយោបាយ ។

ក្នុងគោលបំណងពង្រឹងនីតិរដ្ឋដោយយកចិត្តទុកដាក់គោរពច្បាប់ លិខិតបទដ្ឋានជាធរមាន និងដើម្បីប្រសិទ្ធភាពនៃការងារ យុត្តិធម៌ និងសមធម៌ ពិសេសដើម្បីអោយគ្រប់ក្រសួង-ស្ថាប័ន បំពេញការងារប្រកបដោយនិរន្តរភាព និងរ៉ាប់រងភារៈទទួលខុសត្រូវរបស់ខ្លួនបានតាមរបៀបជាក្រសួងដែលមានការឯកភាពរវាងថ្នាក់ដឹកនាំមកពីគណបក្សទាំងពីរនោះ រាជរដ្ឋាភិបាល កំណត់នូវគោលការណ៍ និងនីតិវិធីក្នុងការរៀបចំតែងតាំងមន្ត្រីរាជការទូទៅដូចតទៅ :

-ត្រូវមានការពិគ្រោះយោបល់ផ្ទៃក្នុងថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន រវាងគណបក្សទាំងពីរ ដើម្បីជ្រើសរើសមន្ត្រីដែលមានសមត្ថភាពពិតប្រាកដ មានគុណសម្បត្តិ និងបទពិសោធន៍ក្នុងការងារ ស្របតាមសេចក្តីត្រូវការនៃសំណូមពរការងារ និងដើម្បីផលប្រយោជន៍រួមរបស់ក្រសួង-ស្ថាប័ន ក៏ដូចជារាជរដ្ឋាភិបាល ។

-ត្រូវប្រគល់ភារកិច្ចអោយនាយកដ្ឋានបុគ្គលិក នៃក្រសួង-ស្ថាប័នសាមីរៀបចំបែបបទស្នើសុំតែងតាំងតាមនីតិវិធីផ្លូវច្បាប់ជាធរមាន ដោយមានការត្រួតពិនិត្យរដ្ឋបាលពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីពិនិត្យ សំរេច ឬសុំការសម្រេចតាមសមត្ថកិច្ច ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត -ក្រុង ត្រូវចាត់តាំងអនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៥

ហ៊ុន សែន

**ចម្លងជាយ និង ជូន :**
-សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និងជាព្រះប្រធានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និង គ្រប់ខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ